ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ឯកសារជំនួយស្មារតីគ្រូបណ្តុះបណ្តាល

# តួនាទីយេនឌ័រ និងការបង្កើនសិទ្ធអំណាចផ្នែកសេដ្ឋកិច្ច ដល់ស្ត្រីក្នុងវិស័យកសិកម្ម

# Gender Role and Women Economic Empowerment in Agriculture



**រៀបចំដោយ:** កម្មវិធីផ្សព្វផ្សាយកសិកម្មថ្មីដែលធន់ទៅនឹង ការប្រែប្រួលអាកាសធាតុ (ASPIRE)

**ឧបត្ថម្ភដោយ:** រាជរដ្ឋាភិបាលកម្ពុជា និងមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍកសិកម្ម (IFAD)

IFAD
Investing in rural people

ភ្នំពេញ ខែ មីនា ឆ្នាំ ២០១៧

# មាតិកា

ទំព័រ


សេចក្តីថ្លែងអំណរគុណ ........................................................................................................4

ការណែនាំឲ្យស្គាល់គ្នាទៅវិញទៅមក ....................................................................................5

សំណួរសាកល្បងមុនវគ្គបណ្តុះបណ្តាល..................................................................................6

ការបង្ហាញពីគោលបំណង ការរំពឹងទុក និងរបៀបវារៈ ...............................................................7

គោលការណ៍ក្រុម ឬ វគ្គ ......................................................................................................9

គោលនយោបាយ និងក្របខណ្ឌយុទ្ធសាស្ត្របញ្ជ្រាប យេនឌ័រក្នុងវិស័យកសិកម្ម និងតួនាទីភារកិច្ចអ្នកពាក់ព័ន្ធ ......................................................................................................................10

ការផ្តល់ ឬការបង្កើនសិទ្ធអំណាច ផ្នែកសេដ្ឋកិច្ចដល់ស្ត្រី.........................................................14

លំហាត់ចាប់ផ្តើម ...............................................................................................................15

ផ្នត់គំនិតយេនឌ័រ ..............................................................................................................17

ការវិភាគយេនឌ័រ...............................................................................................................21

ការរើសអើងទាក់ទងនឹងយេនឌ័រ ........................................................................................22

ការវិភាគ តួនាទីយេនឌ័រក្នុងរបរកសិកម្ម...............................................................................22

យេនឌ័រ នឹងអំណាច...........................................................................................................22

ការផ្តល់ភាពអង់អាចដល់ស្ត្រី ..............................................................................................26

សំណួរសាកល្បងក្រោយវគ្គបណ្តុះបណ្តាល ......................................................................31

ការវាយតម្លៃដោយកសិករ ..............................................................................................32

សំណួរសាកល្បង មុន និងក្រោយវគ្គបណ្តុះបណ្តាល ..........................................................33

ទម្រង់វាយតម្លៃវគ្គបណ្តុះបណ្តាល ប្រចាំថ្ងៃរបស់កសិករ.....34
តារាងកំណត់ត្រាសង្ខេបលទ្ធផលនៃការពិភាក្សាតាមក្រុមសម្រាប់អ្នកសម្របសម្រួល.....35
វគ្គបណ្តុះបណ្តាល ស្តីពីតួនាទីយេនឌ័រ និងការបង្កើនសិទ្ធអំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីក្នុងវិស័យកសិកម្ម .....38
ឯកសារយោង.....43

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមសម្តែងនូវកតញ្ញូតាធម៌ និង ដឹងគុណយ៉ាងជ្រាលជ្រៅចំពោះម្ចាស់ជំនួយ មូលនិធិអន្តរជាតិអភិវឌ្ឍកសិកម្ម (IFAD) ដែលបានផ្តល់កម្ចីដល់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទក្នុងការអនុវត្ត កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE) និងអង្គភាពគាំទ្រគម្រោងយេនឌ័រ និងកុមារនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (GCPSU-MAFF)ដែលបានចូលរួមពិនិត្យនិងផ្តល់ប្រឹក្សា។ ឯកសារណែនាំនេះគោលបំណង កាត់បន្ថយភាពក្រីក្រ និងបង្កើនភាពធន់ របស់គ្រួសារ កសិករក្រីក្រ និងអ្នកងាយរងគ្រោះខ្នាតតូចនៅកម្ពុជា។ កម្មវិធីបានផ្តល់ថវិកា ដល់អគ្គនាយកដ្ឋានកសិកម្ម/នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ក្នុងការអនុវត្ត សមាសភាពទី២ នៃកម្មវិធីគឺអភិវឌ្ឍសមត្ថភាពសេវាផ្សព្វផ្សាយកសិកម្ម ដើម្បីជួយគាំទ្រការកែលម្អសេវាផ្សព្វផ្សាយកសិកម្ម នៅថ្នាក់ក្រោមជាតិ និងមូលដ្ឋានតាមរយៈបង្កើនគុណភាពផ្សព្វផ្សាយកសិកម្ម និងគ្រប់គ្រងចំណេះដឹង និងពង្រឹងធនធានមនុស្សសម្រាប់ ផ្សព្វផ្សាយកសិកម្ម។

កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ មានគោលបំណងក្នុងការលើកកម្ពស់ឱកាសសេដ្ឋកិច្ចរបស់កសិករស្ត្រីក្រីក្រ ឲ្យកាន់តែមានភាពប្រសើរឡើង ដោយឆ្លងកាត់ការផ្តល់ឱកាសឲ្យស្ត្រីបញ្ចេញសម្លេង ធ្វើការសម្រេចចិត្តនៅក្នុងកម្មវិធី និងសកម្មភាពផ្សព្វផ្សាយកសិកម្ម។

យើងសង្ឃឹមថាឯកសារនេះ និងជួយដល់ មន្ត្រីផ្សព្វផ្សាយ ភ្នាក់ងារផ្សព្វផ្សាយ ក្នុងការកសាងសមត្ថភាព និងការអភិវឌ្ឍន៍ធនធានមនុស្សផ្នែកយេនឌ័រ និងកសិកម្ម ក៏ដូចជាការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីជនបទ ។

ឯកសារណែនាំ "**តួនាទីយេនឌ័រនិងការបង្កើនសិទ្ធអំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីក្នុងវិស័យកសិកម្ម**" នេះជាសមិទ្ធិផលថ្មីមួយរបស់កម្មវិធី ASPIRE ភាពជោគជ័យក្នុងដំណើរ ការរៀបចំសៀវភៅនេះ គឺអាស្រ័យទាំងស្រុងលើកិច្ចសហប្រតិបត្តិការ និងការចូលរួមក្រុមការងារបច្ចេកទេស របស់កម្មវិធីនៃ អគ្គនាយកដ្ឋានកសិកម្ម/នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ។

# ការណែនាំឲ្យស្គាល់គ្នាទៅវិញទៅមក

**គោលបំណង**: ដើម្បីផ្តល់ឱកាសដល់អ្នកចូលរួមអាចៈ
- រៀបរាប់ឈ្មោះគ្នាទៅវិញទៅមក
- បង្កើតបរិយាកាសល្អ និងភាពស្និតស្នាលទៅវិញទៅមក

**វិធីសាស្ត្រ**:
- ចាប់ដៃគូ
- និយាយរឿងប្រាប់គ្នាទៅវិញទៅមក

**សម្ភារៈ**: ក្រដាសផ្ទាំងធំ ក្រដាសពណ៌កាត់ជារាងមូល ហ្វឺត ស្កុត

**រយៈពេល**: ១០ នាទី

**ដំណើរការ**:

១. អ្នកសម្របសម្រួលសុំឲ្យអ្នកចូលរួមឈរជាពីរជួរ អ្នកដែលមានអាយុតិចជាងគេឈរមុខ ។ ចុងក្រោយសុំឲ្យអ្នកចូលរួមបែរមុខរកគ្នានឹងចាប់ដៃគូគ្នា

២. អ្នកសម្របសម្រួល ផ្តល់ជូននូវក្រដាសពណ៌ដែលកាត់ជារាងមូល និង ហ្វឺត ដើម្បីឲ្យគេសរសេរឈ្មោះ

៣. អ្នកសម្របសម្រួលសរសេរសំនួរដាក់លើក្រដាសផ្ទាំងធំ

- **តើអ្នកឈ្មោះអ្វី ?**
- **អ្នកណាជាអ្នកដាក់ឈ្មោះឲ្យអ្នក ?**

  បន្ទាប់មកឲ្យពួកគេសរសេរឈ្មោះឲ្យគ្នាទៅវិញទៅមកនៅលើក្រដាសរាងមូលដែលអ្នកសម្របសម្រួលចែកឲ្យ

៤. ពេលអស់ម៉ោង ស្នើឲ្យអ្នកចូលរួមឡើងមកបង្ហាញម្តងមួយគូរម្តងៗរហូតដល់អស់

- **តើអ្នកមានអារម្មណ៍យ៉ាងណាចំពោះការចូលរួមធ្វើលំហាត់នេះ?**

៥. អ្នកសម្របសម្រួលប្រាប់អ្នកចូលរួមពីគោលបំណងនៃលំហាត់នេះ គឺធ្វើឡើងដើម្បីបង្កើតឱកាសឲ្យអ្នកចូលរួមស្គាល់ឈ្មោះគ្នាទៅវិញទៅមក និងបង្កើនភាពស្និទ្ធស្នាលរវាងគ្នាផងដែរ។

# សំណួរសាកល្បងមុនវគ្គបណ្តុះបណ្តាល

**គោលបំណង**: ដើម្បីវាស់ស្ទង់ចំណេះដឹងរបស់កសិករមុនពេលទទួលវគ្គបណ្តុះបណ្តាល

**វិធីសាស្ត្រ**: អ្នកសម្របសម្រួលសួរសំណួរដែលបានសរសេររួចចំនួនបីសំណួរជារួម ដោយឲ្យសិក្ខាកាមលើកដៃឆ្លើយ និងសំណួរ និងកត់ចំនួនអ្នកឆ្លើយក្នុងក្រដាស

**សម្ភារៈ**: ក្រដាសសំណួរសាកល្បង ប៊ិច ឬ ខ្មៅដៃ

**រយៈពេល**: ១០នាទី

**ដំណើរការ**:

១.អ្នកសម្របសម្រួលប្រាប់សិស្សថា មុននិងចាប់ផ្តើមវគ្គ សូមអ្នកទាំងអស់គ្នាឆ្លើយដោយផ្ទាល់មាត់ ទៅនិងសំណួរដែលយើងទាក់ទងនិងមេរៀនដែលនិងបណ្តុះបណ្តាលក្នុងថ្ងៃនេះទាក់ទង និង ការបង្កើនសិទ្ធអំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ដើម្បីវាស់វែងចំណេះដឹងអ្នកទាំងអស់គ្នា

២.អ្នកសម្របសម្រួល កត់ត្រាចំនួនអ្នកឆ្លើយក្នុងក្រដាស

៣.អ្នកសម្របសម្រួលធ្វើការបូលសរុប និងដាក់ពិន្ទុត្រួសៗ ដើម្បីរៀបចំមេរៀនឲ្យឆ្លើយទៅនឹងចំណេះដឹងរបស់អ្នកចូលរួម

# ការបង្ហាញពីគោលបំណង ការរំពឹងទុក និងរបៀបវារៈ

**គោលបំណង**: ដើម្បីផ្តល់ឱកាសដល់អ្នកចូលរួមអាចៈ

- កំណត់បាននូវគោលបំណងចម្បងរបស់វគ្គ និងប្រធានបទជាបន្តបន្ទាប់ដែល នឹងត្រូវលើកយកមកពិភាក្សា
- អ្នកចូលរួមនឹងអាចរៀបរាប់បាននូវអ្វីដែលគេគិតថាទទួលបានពីវគ្គបណ្តុះបណ្តាល

**វិធីសាស្រ្ត**:

- សំនួរបំផុសគំនិត ធ្វើបទបង្ហាញ និង
- អានឯកសារ

**សម្ភារៈ**: គោលបំណងនៃវគ្គសរសេរលើក្រដាសផ្ទាំងធំ ស្កុត

**រយៈពេល**: ១០នាទី

**ដំណើរការ**:

១.អ្នកសម្របសម្រួល ស្នើឲ្យអ្នកចូលរួមអង្គុយជាអក្សរ U ដើម្បីងាយស្រួលមើលគ្នាទៅវិញទៅមក

២.អ្នកសម្របសម្រួលនិយាយទៅកាន់អ្នកចូលរួមៈ

កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE) មានគោលបំណងក្នុងការលើកកម្ពស់ឱកាសសេដ្ឋកិច្ចរបស់ស្រ្តីកសិករក្រីក្រ ឲ្យកាន់តែមានភាពប្រសើរឡើង ដោយឆ្លងកាត់ការផ្តល់**ឱកាសឲ្យស្រ្តីបញ្ចេញសម្លេង និងធ្វើការសម្រេចចិត្ត**។

ដូច្នេះ គោលបំណងសំខាន់ក្នុងវគ្គនេះគឺៈ

- ធ្វើការឆ្លុះបញ្ចាំងអំពីការរស់នៅ ការប្រកបរបរចិញ្ចឹមជីវិត និងតួនាទីក្នុងសហគមន៍របស់ស្រ្តីក្រីក្រ នៅតាមជនបទដែលបាត់បង់ឱកាស
- ស្វែងរក និងគៀងគរការចូលរួមគាំទ្រ ការលើកកម្ពស់ ការទទួលស្គាល់ និងឲ្យតម្លៃស្រ្តីក្នុងសកម្មភាពចូលរួមរកប្រាក់ ចំណូល និងសកម្មភាពដឹកនាំក្រុម ឬសហគមន៍ ពីសំណាក់ដៃគូរបុរស សហគមន៍ មន្ទីរវិស័យ និងអាជ្ញាធមូលដ្ឋាន

៣. អ្នកសម្របសម្រួល បង្ហាញដោយសង្ខេប ពីគោលបំណងនៃវគ្គបណ្តុះបណ្តាលដូចក្នុងក្រដាសផ្ទាំងធំ ។ សុំឲ្យសិស្សដែលស្ម័គ្រចិត្ត ២ ទៅ ៣នាក់ អាននូវចំណុចទាំងនោះ

៤. បន្ទាប់មក អ្នកសម្របសម្រួលបង្ហាញនូវរបៀបវារៈក្នុងវគ្គ